ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# លិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវិស័យដំណាំ

| ល.រ | លេខលិខិត | ថ្ងៃខែលិខិត | របស់ | កម្មវត្ថុនៃលិខិត |
|---|---|---|---|---|
| ១ | លិខិតគ្មានលេខ | ២៩-សីហា-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សេចក្តីជូនដំណឹង ស្តីពី ការនាំចេញផលិតផលកសិកម្ម៦មុខទៅប្រទេសចិន |
| ២ | លិខិតលេខ ១០៣ ប្រក.កសក.ប | ០៧-កុម្ភៈ-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី ការបង្កើតក្រុមប្រឹក្សាពូជដំណាំ |
| ៣ | លិខិតលេខ ១០៤ ប្រក.កសក.ប | ០៧-កុម្ភៈ-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី ការបង្កើតគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ |
| ៤ | លិខិតលេខ ១៦៣ អនក្រ.បក | ០៧-វិច្ឆិកា-២០១៩ | រាជរដ្ឋាភិបាលកម្ពុជា | អនុក្រឹត្យ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# សេចក្តីជូនដំណឹង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាម្ចាស់រោងចក្រកែច្នៃវេចខ្ចប់ផលិតផលកសិកម្ម និងម្ចាស់កសិដ្ឋាន ជ្រាបថាយោងតាមផែនការសកម្មភាពស្តីពីការជំរុញដំណើរការភូតគាមអនាម័យ សម្រាប់នាំចេញផ្លែស្វាយកម្ពុជាទៅកាន់សាធារណរដ្ឋប្រជាមានិតចិន រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ និងសេចក្តីថ្លែងការណ៍រួមចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គរដ្ឋបាលគយចិន និងអង្គការអភិវឌ្ឍន៍ឧស្សាហកម្មនៃសហប្រជាជាតិ ផលិតផលកសិកម្មចំនួន០៦មុខរួមមាន ផ្លែស្វាយស្រស់ ផ្លែមៀនប៉ៃលិន ផ្លែស្រកានាគ ផ្លែដូងក្រអូប ម្រេច និងទឹកមាត់ក្រពើ ត្រូវបានជ្រើសរើសជាមុខទំនិញអាទិភាពសម្រាប់ជំរុញការនាំចេញទៅកាន់ទីផ្សារសាធារណរដ្ឋប្រជាមានិតចិន ក្នុងបណ្តាឆ្នាំខាងមុខនេះ។ ដើម្បីអាចធ្វើការនាំចេញផលិតផលទាំងនោះទៅកាន់ទីផ្សារសាធារណរដ្ឋប្រជាមានិតចិន ជាផ្លូវការនោះ ភាគីចិនតម្រូវឱ្យភាគីកម្ពុជាបំពេញតាមលក្ខខណ្ឌតម្រូវអនាម័យ និងភូតគាមអនាម័យ ព្រមទាំងបទដ្ឋានសុវត្ថិភាពម្ហូបអាហារពាក់ព័ន្ធដែលមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានរបស់សាធារណរដ្ឋប្រជាមានិតចិន។

អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនឹងអនាម័យ និងភូតគាមអនាម័យនៃប្រទេសទាំងពីរនឹងដំណើរការចរចាគ្នាអំពីលក្ខខណ្ឌតម្រូវអនាម័យ និងភូតគាមអនាម័យ សម្រាប់ផលិតផលនីមួយៗខាងលើ ព្រមទាំងចុះត្រួតពិនិត្យ និងវាយតម្លៃនៅលើទីវាលផ្ទាល់នៅតាមបណ្តាកសិដ្ឋាន និងទីតាំងកែច្នៃវេចខ្ចប់។ ដូចនេះ ដើម្បីឱ្យដំណើរការចរចា ប្រព្រឹត្តទៅបានដោយរលូន និងឆាប់រហ័សនោះ សូម អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីជាម្ចាស់រោងចក្រកែច្នៃវេចខ្ចប់ផលិតផលកសិកម្ម និងម្ចាស់កសិដ្ឋានដែលមានបំណងនាំចេញផលិតផលខាងលើទៅកាន់ទីផ្សារសាធារណរដ្ឋប្រជា-មានិតចិន ធ្វើការទំនាក់ទំនងដាក់ពាក្យស្នើសុំចុះបញ្ជីនៅនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ដើម្បីចាត់មន្ត្រីជំនាញចុះពិនិត្យ និងណែនាំផ្នែកបច្ចេកទេសជូនតាមភាពជាក់ស្តែង ដើម្បីធានាបាននូវអនុលោមភាពតាមលក្ខខណ្ឌតម្រូវអនាម័យ និងភូតគាមអនាម័យរបស់សាធារណរដ្ឋប្រជាមានិតចិន ឱ្យបានរួចរាល់មុនពេលអង្គភាពមានសមត្ថកិច្ចប្រទេសទាំងពីរចុះពិនិត្យ និងវាយតម្លៃផ្ទាល់នៅតាមបណ្តាកសិដ្ឋាន និងទីតាំងកែច្នៃវេចខ្ចប់រួចទើបអនុញ្ញាតឱ្យធ្វើការនាំចេញ។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ៖០១២ ៣២៥ ៥៥៨, ០១២ ៥៣៣ ៦៤៧ និង ០៧៧ ៤២៦ ៦០៨។

ថ្ងៃព្រហស្បតិ៍ ១៤ [illegible] ខែ[illegible] ឆ្នាំកុរ ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 217 320

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១០៣ ប្រក កសក ៗ

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សាពូជដំណាំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមគោលនយោបាយពូជដំណាំនៅកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាពូជដំណាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យតាមដាន និងតម្រង់ទិសការអភិវឌ្ឍឧស្សាហកម្មពូជដំណាំនៅកម្ពុជា។

**ប្រការ ២.-**

ក្រុមប្រឹក្សាពូជដំណាំមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. តំណាងអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៣. តំណាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | អនុប្រធាន |
| ៤. តំណាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ៥. តំណាងក្រុមហ៊ុននាំចេញនាំចូលកសិផល | សមាជិក |
| ៦. តំណាងវិស័យឯកជនធ្វើអាជីវកម្មពាក់ព័ន្ធនឹងពូជដំណាំ | សមាជិក |
| ៧. អ្នកមានបទពិសោធន៍ពាក់ពន្ធ័នឹងពូជដំណាំ | សមាជិក |
| ៨. តំណាងសហគមន៍កសិកម្ម | សមាជិក |
| ៩. តំណាងនាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម | លេខាធិការ។ |

សមាសភាពក្រុមប្រឹក្សាពូជដំណាំ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៣.-**

ក្រុមប្រឹក្សាពូជដំណាំមានអាណត្តិរយៈពេល៥ឆ្នាំ ហើយសមាជិកដែលត្រូវតែងតាំងនៅក្នុងក្រុមប្រឹក្សាពូជដំណាំនេះ ត្រូវមានបទពិសោធន៍ពាក់ពន្ធ័នឹងពូជដំណាំ។ ក្រុមប្រឹក្សាពូជដំណាំនេះ អាចអញ្ជើញអ្នកមានបទពិសោធន៍ពាក់ពន្ធ័នឹងប្រភេទពូជដំណាំដែលត្រូវស្នើសុំបញ្ជូលឱ្យចូលរួមការប្រជុំ ប្រសិនបើមានការចាំបាច់។ អ្នកមានបទពិសោធន៍ពាក់ពន្ធ័ទាំងនោះអាចចូលរួមផ្តល់មតិ និងយោបល់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត ឬចូលរួមធ្វើការអនុម័តនោះទេ។

**ប្រការ៤.-**

ក្រុមប្រឹក្សាពូជដំណាំមានភារកិច្ចដូចតទៅ៖

- ផ្តល់ការណែនាំនិងតម្រង់ទិសក្នុងការកសាងនិងអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ពូជដំណាំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅកម្ពុជា
- តាមដាននិងពិនិត្យការផលិត ការទុកដាក់ពូជដំណាំ ចរាចរណ៍ពូជដំណាំនៅលើទីផ្សារ និងដំណើរការចុះបញ្ជីប្រភេទពូជដំណាំ តាមតម្រូវការចាំបាច់
- ផ្តល់ការណែនាំក្នុងការដោះស្រាយវិវាទផ្សេងៗ នៅក្នុងវិស័យពូជដំណាំ
- លើកទឹកចិត្តដល់បុគ្គល អង្គភាពសាធារណៈ ក្រុមហ៊ុន ឬសហគមន៍ ដែលមានស្នាដៃនៅក្នុងការផលិត ឬចែកចាយពូជដំណាំ
- សម្របសម្រួលកៀរគរថវិកាចាំបាច់សម្រាប់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំនៅកម្ពុជា។

**ប្រការ ៥.–**

នាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវផ្តល់ការគាំទ្រផ្នែករដ្ឋបាលនិងបច្ចេកទេសដល់ក្រុមប្រឹក្សាពូជដំណាំ ដូចខាងក្រោម៖

- ប្រមូលចងក្រងនិងរៀបចំរាល់ព័ត៌មានចាំបាច់អំពីការផលិត ការទុកដាក់ និងចរាចរណ៍ពូជដំណាំ
- ប្រមូលចងក្រងនិងរៀបចំរាល់ព័ត៌មានចាំបាច់អំពីសម្តែងកម្មនៃគ្រប់ប្រភេទពូជដំណាំដែលបានបញ្ចេញឱ្យប្រើប្រាស់
- រៀបចំកិច្ចប្រជុំនិងឯកសារប្រជុំជូនសមាជិកនៃក្រុមប្រឹក្សាពូជដំណាំយ៉ាងតិច៥ថ្ងៃ មុនការប្រជុំ
- រៀបចំកំណត់ហេតុនៃការប្រជុំនីមួយៗរបស់ក្រុមប្រឹក្សាពូជដំណាំ
- រៀបចំរបាយការណ៍លទ្ធផលស្តីពីការសម្រេចរបស់ក្រុមប្រឹក្សាពូជដំណាំដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីពិនិត្យនិងសម្រេចជាចុងក្រោយ។

**ប្រការ ៦.–**

ក្រុមប្រឹក្សាពូជដំណាំត្រូវជួបប្រជុំពិភាក្សាការងារយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ឬតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាពូជដំណាំ ជាការចាំបាច់។ ការសម្រេចរបស់គណៈកម្មាធិការនេះ ត្រូវផ្អែកលើការព្រមព្រៀងគ្នាជាឯកច្ឆន្ទ។ ក្នុងករណីពុំអាចសម្រេចបានការព្រមព្រៀងគ្នាជាឯកច្ឆន្ទ ត្រូវអនុម័តតាមគោលការណ៍ ៥០%(ហាសិបភាគរយ) បូក១ (មួយ)។

**ប្រការ ៧.–**

ការចំណាយសម្រាប់ដំណើរការរបស់ក្រុមប្រឹក្សាពូជដំណាំ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ថវិការបស់ក្រុមប្រឹក្សាពូជដំណាំអាចទទួលបានពីប្រភពផ្សេងៗទៀត តាមរយៈជាជំនួយ ជាគម្រោងនានា ឬជាលក្ខណៈពាណិជ្ជកម្មផ្សេងៗ ។

**ប្រការ ៨.–**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ០៧ ខែ កុម្ភៈ ឆ្នាំ២០១៩

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៨
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១០៤ ប្រក. កសក ៥

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមគោលនយោបាយពូជដំណាំនៅកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យទៅលើដំណើរការវាយតម្លៃ ធ្វើសេចក្តីសម្រេចចិត្តក្នុង ការបញ្ចេញប្រភេទពូជថ្មីនៃដំណាំ និងពិនិត្យទៅលើបញ្ជីឈ្មោះប្រភេទពូជដំណាំ។

**ប្រការ ២.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. | តំណាងអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៣. | តំណាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | អនុប្រធាន |
| ៤. | តំណាងនាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ៥. | តំណាងវិស័យឯកជនធ្វើអាជីវកម្មពាក់ព័ន្ធនឹងពូជដំណាំ | សមាជិក |
| ៦. | តំណាងក្រុមផលិតពូជដំណាំ | សមាជិក |
| ៧. | តំណាងនាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម | លេខាធិការ។ |

សមាសភាពគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំមានអាណត្តិរយៈពេល៥ឆ្នាំ ហើយសមាជិកដែលត្រូវតែងតាំងនៅក្នុងគណៈកម្មាធិការ ត្រូវមានបទពិសោធន៍ពាក់ពន្ធ័នឹងពូជដំណាំ។ គណៈកម្មាធិការនេះ អាចអញ្ជើញអ្នកមានបទពិសោធន៍ពាក់ពន្ធ័នឹងប្រភេទពូជដំណាំដែលត្រូវស្នើសុំបញ្ចេញឱ្យចូលរួមការប្រជុំ ប្រសិនបើមានការចាំបាច់។ អ្នកមានបទពិសោធន៍ពាក់ពន្ធ័ទាំងនោះ អាចចូលរួមផ្តល់មតិ យោបល់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត ឬចូលរួមធ្វើការអនុម័តនោះទេ។

**ប្រការ ៤.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចបញ្ចេញប្រភេទពូជថ្មីនៃដំណាំ
- សម្រេចអំពីប្រភេទដំណាំដែលត្រូវដាក់ចូលក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ
- សម្រេចអំពីប្រភេទពូជដំណាំដែលមានស្រាប់ណាខ្លះដែលត្រូវដាក់បញ្ចូលក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិលើកដំបូង
- ពិនិត្យនិងអនុម័តពិធីសារពិសោធន៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃរាល់ប្រភេទដំណាំ
- ចុះពិនិត្យទីតាំងពិសោធន៍នៅក្នុងដំណាក់កាលលូតលាស់នៃដំណាំ ដើម្បីតាមដានអំពីស្ថានភាពលូតលាស់ និងសម្តែងកម្មនៃពូជដែលកំពុងធ្វើការពិសោធន៍វាយតម្លៃនៅទីវាល តាមការចាំបាច់
- ទទួលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធស្តីពីការប្រើប្រាស់និងគុណប្រយោជន៍នៃប្រភេទពូជដំណាំដែលបានចុះបញ្ជី។

**ប្រការ ៥.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំត្រូវជួបប្រជុំពិភាក្សាការងារយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ឬតាមការស្នើសុំ របស់ប្រធានគណៈកម្មាធិការ ជាការចាំបាច់។ ការសម្រេចរបស់គណៈកម្មាធិការនេះ ត្រូវផ្អែកលើការព្រមព្រៀងគ្នាជាឯកច្ឆន្ទ។ក្នុងករណីពុំអាចសម្រេចបានការព្រមព្រៀងជាឯកច្ឆន្ទត្រូវអនុម័តតាមគោលការណ៍ ៥០%(ភាគរយ)បូក១(មួយ)។

**ប្រការ ៦.-**

នាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងបច្ចេកទេស ដល់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ដូចខាងក្រោម៖

- ប្រមូលចងក្រងនិងរៀបចំរាល់ព័ត៌មានដែលចាំបាច់អំពីប្រភេទពូជដំណាំដែលស្នើសុំបញ្ចេញឱ្យប្រើប្រាស់
- រៀបចំកិច្ចប្រជុំនិងឯកសារប្រជុំជូនដល់សមាជិកនៃគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំយ៉ាងតិច ១៥ថ្ងៃ មុនការប្រជុំ
- រៀបចំកំណត់ហេតុនៃការប្រជុំនីមួយៗរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ
- ធ្វើបច្ចុប្បន្នភាពបញ្ជីប្រភេទពូជដំណាំ ដោយអនុលោមទៅតាមការសម្រេច និងការណែនាំរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ
- រៀបចំរបាយការណ៍លទ្ធផលស្តីអំពីការសម្រេចរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីពិនិត្យនិងសម្រេចជាចុងក្រោយ។

**ប្រការ ៧.-**

ការចំណាយសម្រាប់ដំណើរការរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំត្រូវផ្គត់ផ្គង់ ដោយថវិកាជាតិក្នុងគម្រោងថវិការបស់អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ថវិការបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ក៏អាចទទួលបានពីប្រភពផ្សេងៗទៀត តាមរយៈជាជំនួយ ជាគម្រោងនានា ឬជាលក្ខណៈពាណិជ្ជកម្មផ្សេងៗ។

**ប្រការ ៨.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ខែ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៨
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦៣ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ........៣៥៩២........
ថ្ងៃទី០៨...១១.១៩...
បញ្ជូន........................

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្មក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/.

- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១ ..**

ត្រូវបានបង្កើតនាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២ ..**

នាយកដ្ឋានពូជដំណាំមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ កសាងផែនការយុទ្ធសាស្ត្រ ផែនការថវិកា កម្មវិធី និងគម្រោងអភិវឌ្ឍពូជដំណាំ ក្នុងគោលដៅលើកកម្ពស់គុណភាពនិងការផ្គត់ផ្គង់ពូជដំណាំប្រកបដោយប្រសិទ្ធភាពខ្ពស់
- រៀបចំកសាងនិងអនុវត្តបទដ្ឋានគតិយុត្តដែលស្ថិតនៅក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ គោលនយោបាយ ពូជដំណាំ ស្តង់ដា និងគោលការណ៍ណែនាំបច្ចេកទេសនានា
- គ្រប់គ្រងនិងផ្តល់ការបណ្តុះបណ្តាល ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្ត ស្តង់ដាពូជដំណាំ និងការត្រួតពិនិត្យគុណភាពពូជដំណាំគ្រប់ប្រភេទ
- ត្រួតពិនិត្យនិងវាយតម្លៃគុណភាពពូជដំណាំនៅគ្រប់ទីតាំងផលិតកម្មនិងនៅមន្ទីរពិសោធន៍ដោយសហការជាមួយនឹងអង្គភាពពាក់ព័ន្ធដើម្បីផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ
- ធ្វើអធិការកិច្ចអាជីវកម្មពូជដំណាំនៅឃ្លាំងស្តុកនិងនៅទីផ្សារនិងតាមដានការប្រើពូជដំណាំនៅទីវាល
- ពិសោធវាយតម្លៃលក្ខណៈខុសប្លែក ឯកសណ្ឋានភាព និងស្ថិរភាពនៃប្រភេទពូជថ្មី សម្រាប់ចុះបញ្ជីនិងស្នើសុំការពារសិទ្ធិជាម្ចាស់ប្រភេទពូជថ្មីនៃដំណាំ
- រៀបចំបែបបទនិងបង្កើតបញ្ជីប្រភេទពូជដំណាំរបស់ជាតិនិងផ្តល់ព័ត៌មានអំពីសកម្មភាពនិងសេវាកម្មដល់អតិថិជន
- រៀបចំចងក្រងនិងរក្សាព័ត៌មាននិងស្ថិតិស្តីពីផលិតកម្ម ការធ្វើអាជីវកម្ម ការនាំចូល និងនាំចេញពូជដំណាំគ្រប់ប្រភេទ
- រៀបចំបង្កើតប្រព័ន្ធទិន្នន័យគ្រឹះគ្រប់គ្រងប្រព័ន្ធនៃការបញ្ជាក់គុណភាពពូជដំណាំគ្រប់ប្រភេទនិងផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងពូជដំណាំដល់ភាគីពាក់ព័ន្ធ
- សហការអនុវត្តអនុសញ្ញា កិច្ចព្រមព្រៀង និងកិច្ចសហប្រតិបត្តិការ ដែលទាក់ទងនឹងការគ្រប់គ្រងពូជដំណាំនៅថ្នាក់ជាតិនិងអន្តរជាតិ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកសិកម្មប្រគល់ជូន។

**មាត្រា៣ ..**

នាយកដ្ឋានពូជដំណាំដឹកនាំដោយប្រធាន១(មួយ)រូបនិងអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

**មាត្រា៤ ..**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានពូជដំណាំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៥ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៕

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ២០១៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា**
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ២០៣ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមកៈ
-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
"ដើម្បីជូនជ្រាប"
-លោក លោកស្រី អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
"ដើម្បីជ្រាប"

ថ្ងៃ ច័ន្ទ ៧ រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

**ត.ប រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី វុទ្ធី**